00816809

E172/27/corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E172/27 | 00816396-00816397 | 19 Jun 2012 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| សូមមើលឯកសារភ្ជាប់ |

| សេចក្តីលម្អិតនៃការកែតម្រូវ៖ |
|---|
| |

ភាគីស្នើសុំ៖ អង្គជំនុំជម្រះសាលាដំបូង ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 06 / 2012
ម៉ោង (Time/Heure): 10:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

00816810

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

E172/27/Corr-1

អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ: ភាគីទាំងអស់នៃសំណុំរឿងលេខ ០០២** កាលបរិច្ឆេទ: ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

**ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន: លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង; មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ: សាក្សីបន្ទាប់នៅក្នុងដំណាក់កាលនេះនៃសំណុំរឿង ០០២/០១**

បន្ថែមទៅលើអនុស្សរណៈពីមុនៗរបស់អង្គជំនុំជម្រះ ដែលមានឈ្មោះសាក្សីនឹងត្រូវមកផ្តល់សក្ខីកម្ម និងលំដាប់លំដោយនៃការកោះហៅ (ឧ. E172, E172/10, E194 និង E172/24) អង្គជំនុំជម្រះសូមជូនព័ត៌មានបន្ថែមពាក់ព័ន្ធនឹងលំដាប់លំដោយនៃការកោះហៅសាក្សី និងអ្នកជំនាញបន្តបន្ទាប់ឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការនាដំណាក់កាលនេះ។

បន្ទាប់ពីការបន្តសវនាការនៅថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីនានា ដូចខាងក្រោម ៖

TCW-797 *(លើគ្រប់អង្គហេតុទាំងអស់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ដែលគាត់បានដឹង)*

TCW-321 *(លើគ្រប់អង្គហេតុទាំងអស់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ដែលគាត់បានដឹង)*

បន្ទាប់ពីវិស្សមកាលរដូវក្តៅរួច អង្គជំនុំជម្រះនឹងបញ្ចប់ការស្តាប់សក្ខីកម្មសាក្សីទាំងអស់ខាងលើ ដែលមិនទាន់បញ្ចប់មុនពេលវិស្សមកាល ហើយនឹងស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញខាងក្រោមទៅតាមលំដាប់លំដោយ៖

លោក David Chandler *(លើគ្រប់អង្គហេតុទាំងអស់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ទៅតាមជំនាញរបស់គាត់)* (នឹងត្រូវស្តាប់សក្ខីកម្មពីថ្ងៃទី ១៦ ដល់ ២៣ ខែ កក្កដា ឆ្នាំ ២០១២)

TCW-564 *(ក្រសួងការបរទេស៖ ប១ ,ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និង*

E172/27/Corr-1

*ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា)*

TCW-694 *(លើគ្រប់អង្គហេតុទាំងអស់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២ ដែលគាត់បានដឹង)*

TCW-490 *(ក្រសួង៖ ប១ បឹងត្របែក)*

TCW-609 *(ក្រសួង (ឃោសនាការ) និងការអប់រំនយោបាយដោយជនជាប់ចោទ និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១)*

TCW-338 *(ក្រសួង (ឃោសនាការ) និងការអប់រំនយោបាយដោយជនជាប់ចោទ)*

TCW-91 *(ក្រសួង (ឃោសនាការ) និងការអប់រំនយោបាយដោយជនជាប់ចោទ)*

TCCP-28~~186~~ *(ក្រសួង (ឃោសនាការ) និងការអប់រំនយោបាយដោយជនជាប់ចោទ)*

TCCP-142 *(រចនាសម្ព័ន្ធរដ្ឋបាល (ជាតិ))*

ព័ត៌មានបន្ថែមនឹងផ្តល់ជូនទៅតាមពេលវេលាសមស្រប។ អង្គជំនុំជម្រះសូមរំឭកដល់ភាគីថា លំដាប់លំដោយខាងលើអាចនឹងមានការប្រែប្រួល ហើយថា ការស្តាប់សក្ខីកម្មសាក្សីនឹងត្រូវធ្វើឡើងផ្លាស់វេនគ្នា ឬតែកន្លះថ្ងៃនៅពេលដែលការរៀបចំសវនាការប្រកបដោយប្រសិទ្ធភាពតម្រូវឲ្យធ្វើដូច្នេះ។

អង្គជំនុំជម្រះបានទទួលព័ត៌មានថ្មីៗបន្ថែមទៀតទាក់ទិននឹងសុខភាព និងភាពទំនេររបស់សាក្សី ពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងពិចារណាអំពីកត្តានានា ដែលបានលើកឡើងនៅក្នុងញត្តិរបស់សហព្រះរាជអាជ្ញា សុំឲ្យផ្តល់អាទិភាពចំពោះសក្ខីកម្មរបស់សាក្សីដែលមានវ័យចំណាស់ (ឯកសារ E188 និងឧប សម្ព័ន្ធសម្ងាត់ E188.1) និងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ (E188/1) ទៅតាមការកំណត់នៃការរៀបចំសវនាការប្រកបដោយប្រសិទ្ធភាព។ អនុស្សរណៈនេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើទាំងពីរ។